# ព្រឹត្តិបត្រ ស្តីពីបញ្ហាអាជីវកម្ម

កម្ពុជា

លេខ ១៤ សីហា ២០០៧

International Finance Corporation
World Bank Group

MPDF
MEKONG PRIVATE SECTOR DEVELOPMENT FACILITY




## ការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា និងផែនការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

ការដោះស្រាយវិវាទពាណិជ្ជកម្មឱ្យបានឆាប់រហ័ស ងាយស្រួល និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ មានសារៈសំខាន់ណាស់ សំរាប់ធ្វើឱ្យអាជីវកម្មមានទំនុកចិត្តក្នុងការពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ។ ប៉ុន្តែ ការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជាមានលក្ខណៈពិបាក ហើយប្រព័ន្ធដោះស្រាយវិវាទទាំងផ្លូវការ និងមិនផ្លូវការ មិនទាន់ដំណើរការបានសមស្របនៅឡើយ ។[១] អាជីវករទាំងឡាយកំរចាត់ទុកថា ការដោះស្រាយវិវាទនៅតុលាការ ថាជាវិធីល្អដែលនាំទៅកាន់ជោគជ័យណាស់ ។ ប៉ុន្តែ ការដោះស្រាយវិវាទមិនផ្លូវការក៏មានគុណវិបត្តិធំៗដែរ ។ ដូច្នេះហើយ អាជីវកម្មភាគច្រើន សុខចិត្តរងការខាតបង់ និងជៀសវាងឱ្យឆ្ងាយពីវិវាទ ជាជាងប្រើសិទ្ធិស្របច្បាប់របស់ខ្លួនប្តឹងទាមទារអ្វីដែលខ្លួនគួរទទួលបានតាមផ្លូវច្បាប់ ។

វិធានការមួយដែលរដ្ឋាភិបាលកម្ពុជាជ្រើសរើសយក ដើម្បីកែលំអប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា គឺការបង្កើតមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។ បច្ចុប្បន្ននេះ ដៃគូរអភិវឌ្ឍន៍មួយចំនួន កំពុងជួយក្រសួងពាណិជ្ជកម្ម ក្នុងការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។[២] នេះគឺជាជំហានវិជ្ជមានមួយ ។ បទពិសោធន៍របស់ប្រទេសជាច្រើន ដោយរួមបញ្ចូលទាំងប្រទេសដែលមានប្រព័ន្ធតុលាការដែលដំណើរល្អផងដែរ បង្ហាញថា ការបង្កើតយន្តការដោះស្រាយវិវាទពាណិជ្ជកម្ម ក្រៅប្រព័ន្ធតុលាការ[៣] អាចជួយកែលំអបរិយាកាសអាជីវកម្ម ដោយធ្វើឱ្យអាជីវកម្ម អាចដោះស្រាយវិវាទបានយ៉ាងងាយស្រួល និងមានប្រសិទ្ធិភាព ។ ប៉ុន្តែ ប្រសិនបើគេបង្កើតយន្តការនេះ វាជាការចាំបាច់ណាស់ថា មជ្ឈមណ្ឌលនេះត្រូវមានយុត្តិធម៌ ឯករាជ្យ ចំណាយអស់ប្រាក់កាសតិចដើម្បីដោះស្រាយវិវាទ និងមានប្រសិទ្ធិភាព តាំងពីពេលដែលគេចាប់ផ្តើមប្រតិបត្តិការដំបូង ។ កត្តាទាំងនេះនឹងបង្កើតឱ្យមានតម្រូវការលើសេវារបស់មជ្ឈមណ្ឌលនេះ និងធ្វើឱ្យសមាគមអាជីវកម្ម មានទំនុកចិត្តមកលើមជ្ឈមណ្ឌលនេះ ។

ប្រទេសកម្ពុជាបានយល់ដឹងអំពីគោលគំនិត និងការអនុវត្តន៍នៃការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការនេះ ច្បាស់លាស់ហើយ ។ ការកែទម្រង់មួយក្នុងចំណោមការកែទម្រង់ដ៏ជោគជ័យនានារបស់កម្ពុជា គឺក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពលកម្ម សំរាប់ដោះស្រាយវិវាទពលកម្ម យ៉ាងមានប្រសិទ្ធិភាព តាំងពីពេលដែលគេបង្កើតឡើងនៅឆ្នាំ ២០០៣ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្ហាញថា គេអាចបង្កើតស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា ដែលមានគុណភាពខ្ពស់ មានប្រសិទ្ធិភាព និងមិនមានអំពើពុករលួយ ហើយវាក៏បង្ហាញផងដែរ សមាគមអាជីវកម្មមានបំណង ប្រើប្រាស់មជ្ឈត្តការ (និងការផ្សះផ្សារ) ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម ។

### ហេតុអ្វីបានជាការអាចដោះស្រាយវិវាទពាណិជ្ជកម្មបាន មានសារៈសំខាន់

ក្នុងការធ្វើអាជីវកម្ម អាជីវករតែងតែថ្លឹងថ្លែងរវាងហានិភ័យ និងផលចំណេញ ។ ប៉ុន្តែ នៅពេលដែលបរិយាកាស អាជីវកម្មគ្មានស្ថេរភាព ឬ មិនអាចព្យាករទុកមុនបាន នោះវានឹងបង្កការលំបាកក្នុងការថ្លឹងថ្លែងរវាងហានិភ័យ និងផលចំណេញ ។ ហេតុដូច្នេះហើយ ប្រព័ន្ធច្បាប់ល្អ និងច្បាស់លាស់សម្រាប់ការធ្វើអាជីវកម្ម មានសារៈសំខាន់ណាស់ក្នុងការជំរុញវិនិយោគ និងកំណើនសេដ្ឋកិច្ច ។ ប្រទេសជាច្រើនដែលមានប្រព័ន្ធច្បាប់ខ្សោយ និងមានយន្តការដោះស្រាយវិវាទពាណិជ្ជកម្មស្មុគស្មាញ មានកំណើនសេដ្ឋកិច្ចទាប ជាងសក្តានុពល

[១] ព្រឹត្តិប័ត្រស្តីពីបញ្ហាអាជីវកម្មលេខនេះ បង្ហាញនូវគំហើញទាំងឡាយនៃការសិក្សាស្រាវជ្រាវ ស្តីពីវិវាទពាណិជ្ជកម្ម នៅក្នុង ខេត្ត-ក្រុងធំៗចំនួនប្រាំនៃប្រទេសកម្ពុជា របស់ IFC MPDF ដែលគេមិនបានបោះពុម្ពផ្សាយនៅឡើយ ។ ការស្រាវជ្រាវនេះផ្តោតទៅលើអាជីវកម្មជាច្រើនប្រភេទ ចាប់ពីពាណិជ្ជកម្មតូចតាច រហូតដល់ក្រុមហ៊ុនធំៗដែលមានប្រតិបត្តិការនៅច្រើនប្រទេស ។ ប៉ុន្តែ ការសិក្សានេះផ្តោតសំខាន់ទៅលើអាជីវកម្មដែលជាកម្មសិទ្ធិរបស់ និងគ្រប់គ្រងដោយជនជាតិខ្មែរ ។

[២] មាត្រា ១០ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ដែលអនុម័ត ក្នុងខែ មីនា ឆ្នាំ ២០០៦) តម្រូវឱ្យក្រសួងពាណិជ្ជកម្មបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ សម្រាប់ដោះស្រាយវិវាទពាណិជ្ជកម្ម ។ IFC MPDF និងធនាគារអភិវឌ្ឍន៍អាស៊ី កំពុងជួយរដ្ឋាភិបាលពិចារណាអំពីលទ្ធភាពក្នុងការបង្កើតមជ្ឈមណ្ឌលនេះ ។

[៣] ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានទម្រង់ជាការផ្សះផ្សារ មជ្ឈត្តការ ឬ ទាំងពីរទម្រង់ ។ ព្រឹត្តិប័ត្រស្តីពីបញ្ហាអាជីវកម្ម លេខ ៩ ឆ្នាំ២០០៦ ផ្តោតសំខាន់ទៅលើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។ គេអាចទទួលបានព្រឹត្តប័ត្រនេះនៅឯការិយាល័យ IFC MPDF ។

MPDF
MEKONG PRIVATE SECTOR DEVELOPMENT FACILITY

**ព្រឹត្តិបត្រស្តីពីបញ្ហាអាជីវកម្ម** ផ្តល់ជូនលោកអ្នកដែលមានចំណាប់អារម្មណ៍ពីរឿងរ៉ាវទាក់ទិននឹងកិច្ចការអាជីវកម្មនូវសេចក្តីសង្ខេបខ្លីៗ និងសេចក្តីវិភាគលើប្រធានបទដែលពាក់ពន្ធ័នឹងបរិយាកាសអាជីវកម្មនៅកម្ពុជា ។ ព្រឹត្តិបត្រ័នេះមានរួមបញ្ចូលទាំងមតិ និងយោបល់ផ្សេងៗ របស់មជ្ឈដ្ឋានពាក់ពន្ធ័ផងដែរ ។

ព្រឹត្តិបត្រ័នេះ ត្រូវបានបោះពុម្ពឡើងដោយមានការឧបតម្ភពីសំណាក់អង្គការកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលជាស្ថាប័នពហុជំនួយគ្រប់គ្រងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាផ្នែកឯកជននៃក្រុមធនាគារពិភពលោក ។

មតិ ឬយោបល់ទាំងឡាយដែលចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រនេះ មិនតំណាងឱ្យទស្សនៈជាផ្លូវការ របស់អង្គការកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ ឬ IFC ទេ វាគ្រាន់តែផ្តល់ជាព័តិមានយោងបន្ថែមតែប៉ុណ្ណោះ ។

ប្រសិនបើប្រព័ន្ធច្បាប់របស់គេធ្វើការប្រសើរជាងនេះ ។[៤] នេះ ដោយសារតែអាជីវកម្មស្ទាក់ស្ទើរក្នុងការចុះកិច្ចសន្យា ឬធ្វើពាណិជ្ជកម្មផ្សេងៗ នៅពេលដែលគេមិនមានការជឿជាក់ថា ប្រព័ន្ធច្បាប់នឹងអាចអនុវត្តកិច្ចសន្យារបស់គេបាន ។ ការណ៍នេះនាំឱ្យមានកំណើនទាប ហើយធ្វើឱ្យមានការខូចខាត ដល់សកម្មភាពវិនិយោគ ។

ក្នុងករណីប្រទេសកម្ពុជា ថ្វីបើសេដ្ឋកិច្ចមានលក្ខណៈវិជ្ជមាន ដោយមានកំណើនខ្លាំងជាច្រើនឆ្នាំកន្លងមក ប្រព័ន្ធច្បាប់ល្អប្រសើរជាងនេះ នឹងធ្វើឱ្យកម្ពុជាមានវិនិយោគទុនច្រើនជាងនេះទៅទៀត និងប្រហែលជាអាចជំរុញឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងពេលបច្ចុប្បន្ន ។ បើយើងក្រលេកមើលទៅអនាគត ការកែលំអប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្ម និងប្រព័ន្ធច្បាប់នៅកម្ពុជា មានសារៈសំខាន់ណាស់សម្រាប់ឱ្យកម្ពុជារក្សាកំណើនដ៏ខ្ពស់នេះក្នុងរយៈពេលវែង ។ នេះជាហេតុផលដែល ការបង្កើតមជ្ឈមណ្ឌលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាជំហានវិជ្ជមានមួយ ។

## ការដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជា ~ តើអាជីវកម្មធ្វើយ៉ាងដូចម្ដេច?

នៅពេលដែលមានវិវាទពាណិជ្ជកម្ម អាជីវកម្មនៅកម្ពុជាតែងតែយល់ថាជំរើសរបស់គេក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មមានកំរិត ដែលជំរើសទាំងនោះរួមមានៈ ការចរចាគ្នា ការសុំឱ្យមានការដាក់សម្ពាធពីសំណាក់ភាគីទីបីដែលមានឥទ្ធិពល (អ្នកធំ) ឬដោះស្រាយនៅតុលាការ ។ ជាមួយនឹងជំរើសទាំងនេះ អាជីវកម្មតែងតែជ្រើសរើសយកការដើរចេញពីវិវាទ (ឬទទួលយកដំណោះស្រាយមិនសមស្រប) ជាជាងចាត់វិធានការបន្ថែម ដូចជាសុំជំនួយពីភាគីទីបី ឬដោះស្រាយវិវាទនៅតុលាការ ។

ការចរចាគ្នាគឺជាវិធីទីមួយដែលអាជីវកម្មកម្ពុជាប្រកាន់យកដើម្បីដោះស្រាយវិវាទ ហើយអាជីវកម្មកម្ពុជា ភាគច្រើននិយាយថា ការខ្វះនូវជំរើសផ្សេងៗដែលមានប្រសិទ្ធិភាព និងអាចជឿជាក់បានធ្វើឱ្យការចចារ (តែងតែ) ជាជំរើសដ៏ល្អបំផុត ដើម្បីទទួលបានលទ្ធផលដែលគេពេញចិត្ត ។ អាជីវកម្មជាច្រើនក៏និយាយផងដែរថា សំរាប់វិវាទមិនសូវធ្ងន់ធ្ងរ នៅពេលដែលការចរចាបរាជ័យ ជាទូទៅអាជីវកម្មសុខចិត្តទទួលខាត ហើយដើរចេញពីវិវាទជាជាង ប្រើប្រាស់លុយ និងពេលវេលាបន្ថែមដើម្បីដោះស្រាយវិវាទនៅតុលាការ ឬពឹងពាក់ជំនួយពីភាគីទីបីដែលជាអ្នកមានអំណាចឱ្យជួយដោះស្រាយវិវាទ ។

នៅក្នុងការសម្ភាសន៍ថ្មីៗជាមួយ IFC-MPDF អាជីវកម្មកម្រគិតថាការដោះស្រាយវិវាទនៅតុលាការ ជាជម្រើសអាទិភាពរបស់គេសំរាប់ដោះស្រាយវិវាទពាណិជ្ជកម្មនោះទេ ហើយអ្នកគ្រប់គ្រងអាជីវកម្មជាច្រើនដែលបានផ្ដល់សម្ភាសន៍ដល់យើង បានរាយការណ៍ថា ពួកគេមិនដោះស្រាយវិវាទនៅតុលាការទេ លើកលែងតែក្នុងករណីដែលពួកគេមិនអាចជៀសរួច ។ គេកម្រនឹងជួបអាជីវកម្ម ដែលធ្លាប់ដោះស្រាយវិវាទពាណិជ្ជកម្មនៅតុលាការណាស់ ។ អាជីវកម្មជាច្រើន ជាពិសេសអាជីវកម្មតូចៗ បាននិយាយថា ពួកគេកាន់តែមិនដោះស្រាយវិវាទនៅតុលាការទៅទៀត ។ អាជីវករនីមួយៗយល់ថាប្រព័ន្ធច្បាប់មាន គុណវិបត្តិ ច្រើនដូចជា មានការយឺតយ៉ាវ ចំណាយប្រាក់ច្រើន និងមិនអាចទទួលបានយុត្តិធម៌ ។ តាមរយៈការសិក្សានេះ គេឃើញទស្សនៈជាអវិជ្ជមាន ចំពោះប្រព័ន្ធតុលាការមានកំរិតខ្ពស់រហូតដល់ថ្នាក់ថា ទោះបីជាប្រព័ន្ធតុលាការចាប់ ផ្ដើមដំណើរការល្អឥតខ្ចោះ ក៏គេនៅតែត្រូវការពេលជាច្រើនឆ្នាំទៀតដើម្បីស្ដារឡើងវិញនូវទំនុកចិត្តរបស់សហគមអាជីវកម្ម លើប្រព័ន្ធតុលាការ ។

ជាជាងដោះស្រាយវិវាទនៅតុលាការ អាជីវកម្មភាគច្រើននិយាយថា ពួកគេស្នើសុំឱ្យភាគីទីបីដែលមានឥទ្ធិពល និងអំណាចធំជាង (ដូចជាមន្ត្រីរដ្ឋាភិបាល) អោយជួយដោះស្រាយវិវាទ ។ ទំនាក់ទំនងរបៀបអាងបង្អែកមានយូរណាស់មកហើយ នៅប្រទេសកម្ពុជា ហើយមានការរាយការណ៍ស្របគ្នាថា សូម្បីតែអាជីវកម្មធំៗ ក៏ជ្រើសរើសយកការដោះស្រាយវិវាទពាណិជ្ជកម្មតាមមជ្ឈត្តការដែលលក្ខណៈឯកជនមិនផ្លូវការជាមួយភាគីទីបី ជាជាងដោះស្រាយវិវាទនៅតុលាការ ។ នៅក្រៅទីក្រុងភ្នំពេញ អាជីវកម្មជាច្រើនបានរាយការណ៍ថា អ្នកដឹកនាំឃុំ ឬខេត្ត តែងតែដើរតួរជាអ្នកផ្សះផ្សាវិវាទ ។ ជាទូទៅ ពួកគេនិយាយថា ការដោះស្រាយដោយភាគីទីបី ដែលជាអ្នកធំត្រូវចំណាយច្រើន ហើយចំណាយនោះ អាចជាទឹកប្រាក់ ឬជាប់ជំពាក់កាតព្វកិច្ចសងមកវិញ ។ ថ្វីបី អាជីវកម្មរាយការណ៍ថា ពួកគេចូលចិត្តប្រើសេវារបស់ភាគីទីបីដែលជាអ្នកធំ ជាជាងតុលាការ នៅក្នុងការអនុវត្តន៍ជាក់ស្ដែង ពួកគេស្ទាក់ស្ទើរក្នុងការប្រើសេវារបស់ភាគីទីបី ព្រោះពួកគេជឿថា ចំណាយអាចនឹងខ្ពស់ជាងអត្ថប្រយោជន៍ ដែលគេមិនអាចព្យាករបាន ។

## កត្តាដែលធ្វើឱ្យមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការដែលគ្រោងនឹងបង្កើតឡើងទទួលបានជោគជ័យ

*យើងទាំងអស់គ្នាចង់បានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមួយដែលដំណើរការល្អ និងផ្ដល់ផលប្រយោជន៍ដល់ផ្នែកឯកជន និងប្រទេសកម្ពុជា ។ ការចូលរួមរបស់ផ្នែកឯកជនតាមរយៈការពិគ្រោះយោបល់ ក្នុងការបង្កើតមជ្ឈមណ្ឌលនេះ នឹងលើកទឹកចិត្តឱ្យអាជីវកម្មប្រើប្រាស់សេវារបស់មជ្ឈមណ្ឌលនេះ ។ នេះជាគន្លឹះដែលនាំឱ្យមជ្ឈមណ្ឌលនេះទទួលបានជោគជ័យ ។*

**លោក Eric Haythorne**

**អ្នកច្បាប់ជាន់ខ្ពស់ ប្រចាំផ្នែកហិរញ្ញវត្ថុ ឯកជន និងហេដ្ឋារចនាសម្ព័ន្ធ**

**ក្រុមធនាគារពិភពលោក**

ស្របតាមស្មារតីនៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (២០០៦) នាពេលថ្មីៗនេះ ក្រសួងពាណិជ្ជកម្មបានចាប់ផ្ដើមពិគ្រោះយោបល់ជាមួយផ្នែកឯកជន និងមជ្ឈដ្ឋានពាក់ព័ន្ធផ្សេងៗទៀតអំពីអនុក្រិត្យ និងការរៀបចំបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។ បទពិសោធន៍អន្តរជាតិរបស់IFC ក្នុងការបង្កើតមជ្ឈមណ្ឌលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បង្ហាញថា ដំណាក់កាលដំបូង នៃការរៀបចំ និងការបង្កើតមជ្ឈមណ្ឌលនេះ ទាមទារឱ្យមានការពិចារណា និងផែនការយ៉ាងល្អិតល្អន់ ដើម្បីជួយឱ្យមជ្ឈមណ្ឌលនេះទទួលបានជោគជ័យ ។ ផ្អែកលើបទពិសោធន៍របស់IFC កត្តាសំខាន់ដែលអាចនាំទៅរកជោគជ័យមានបរិយាយដូចខាងក្រោម ។

- **មជ្ឈមណ្ឌលត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ផ្នែកឯកជន**

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការគួរតែជាស្ថាប័នពិសេសសម្រាប់ផ្នែកឯកជន ។ ប្រសិនបើគេមិនបានពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយផ្នែកឯកជនទេ ហើយផ្នែកឯកជនមិនបានផ្ដល់យោបល់ក្នុងការបង្កើតស្ថាប័ននេះទេ នោះមជ្ឈមណ្ឌលនេះ ប្រហែលជាមិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់ផ្នែកឯកជនបានទេ ។ ដោយសារមជ្ឈមណ្ឌលនេះពឹងផ្អែកលើតម្រូវការ ដោយស្ម័គ្រចិត្តពីផ្នែកឯកជន ការណ៍ដែលមជ្ឈមណ្ឌលនេះមិនអាចឆ្លើយតបទៅនឹង

[៤] មានភស្តុតាងយ៉ាងជាក់ច្បាស់ថា ប្រទេសដែលមានប្រព័ន្ធច្បាប់ និងប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មខ្សោយ មានកំណើនសេដ្ឋកិច្ចទាបជាង សក្ដានុពលនៃកំណើនសេដ្ឋកិច្ចរបស់ខ្លួន ប្រសិនបើប្រព័ន្ធច្បាប់របស់គេធ្វើការបានល្អ ។ មានភស្តុតាង យ៉ាងមុតមាំថា ការកែលំអបរិយាកាសច្បាប់ និងបទបញ្ញត្តិអាជីវកម្ម ទំនងជាផ្ដល់នូវផលប្រយោជន៍យ៉ាងច្រើន ជួយឱ្យសេដ្ឋកិច្ចកើនឡើង ។ ឧទាហរណ៍ សូមមើលរបាយការណ៍*ការធ្វើអាជីវកម្ម* ធនាគារពិភពលោក S. Djankov, R. La Porta, F. Lopez-de-Silanes, A. Shleifer, ព្រឹត្តប័ត្រសេដ្ឋកិច្ចត្រីមាស ខែ ឧសភា ឆ្នាំ ២០០៣ ។

តម្រូវការរបស់ផ្នែកឯកជន អាចធ្វើឱ្យ មជ្ឈមណ្ឌលនេះមិនអាចដំណើរការបានយូរអង្វែងទេ ព្រោះអាជីវកម្មស្ទាក់ស្ទើរក្នុងការប្រើប្រាស់សេវារបស់មជ្ឈមណ្ឌលនេះ ។ ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ថាសហគមអាជីវកម្ម នឹងមានឱកាស ផ្តល់យោបល់ទាក់ទងការរៀបចំបង្កើតមជ្ឈមណ្ឌលនេះ និងជាពិសេស ទាក់ទងនឹងអនុក្រិត្យដែលនឹងបង្កើត និងពិពិនាអំពីរបៀបដែលមជ្ឈមណ្ឌលនេះ ដំណើរការ ។ គោលបំណងរបស់ក្រសួងពាណិជ្ជកម្ម ដែលអនុញ្ញាតឱ្យផ្នែកឯកជនចូលរួមក្នុងការបង្កើតមជ្ឈមណ្ឌលនេះ ពិតជាមានលក្ខណៈវិជ្ជមាន ហើយវាអាចជួយជំរុញឱ្យមានការយល់ដឹង និងជំនឿចិត្តលើមជ្ឈមណ្ឌលនេះ ។

- **ឯករាជ្យភាព**

*ដើម្បីផ្តល់ផលប្រយោជន៏ដល់អាជីវកម្ម គេគួរបង្កើតមជ្ឈមណ្ឌលមជ្ឈត្តការមួយ ដែលឯករាជ្យពីរដ្ឋាភិបាល ។ មជ្ឈមណ្ឌលមជ្ឈត្តការដែលគ្រប់គ្រងដោយផ្នែកឯកជន គឺជាមជ្ឈមណ្ឌលសមស្រប និងមានឯករាជ្យភាព ។ ដើម្បីឱ្យមជ្ឈមណ្ឌលមជ្ឈត្តការមួយអាចទទួលបានជោគជ័យ មជ្ឈមណ្ឌលនោះមិនត្រូវមានអំពើពុករលួយទេ ។ ជាថ្មីម្តងទៀត ដើម្បីជៀសវាងអំពើពុករលួយ គេគួរឱ្យវិស័យឯកជនគ្រប់គ្រងមជ្ឈមណ្ឌលនេះ ។ មជ្ឈមណ្ឌលនេះគួរជួលបុគ្គលិក ដែលមានគុណភាពខ្ពស់ និងផ្តល់ប្រាក់បៀវត្សរ៍ដែលអាចប្រកួតប្រជែងបាន នោះទើបគេអាចធានាថា មិនមានអំពើពុករលួយកើតឡើង ។*

**ឯកឧត្តម ងួន ម៉េងតិច**

**អគ្គនាយក សភាពាណិជ្ជកម្មភ្នំពេញ**

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវតែមានកេរ្តិ៍ឈ្មោះល្អ ថាជាស្ថាប័នមានឯករាជ្យភាព ប្រសិនបើស្ថាប័ននេះចង់ឱ្យ សមាគមអាជីវកម្មប្រើប្រាស់សេវារបស់ខ្លួន ។ ពួកគេបានគូសបញ្ជាក់ថា បើសិនជាមជ្ឈមណ្ឌលនេះ មិនមានឯករាជ្យភាព និងយុត្តិធម៌ទាំងស្រុងទេ នោះអាជីវកម្មនឹងមិនមកដោះស្រាយវិវាទនៅមជ្ឈមណ្ឌលនេះឡើយ ។ សញ្ញាសំខាន់ ដែលបង្ហាញពី ឯករាជ្យភាព របស់មជ្ឈមណ្ឌលនេះ គឺរដ្ឋាភិបាលដកខ្លួនចេញពីកាចូលរួមដោយសកម្ម ឬដោយផ្ទាល់ក្នុងការគ្រប់គ្រង និងប្រតិបត្តិការរបស់មជ្ឈមណ្ឌល នៅពេលដែលស្ថាប័ននេះចាប់ផ្តើមប្រតិបត្តិការ ។

- **អភិបាលកិច្ចល្អ និងការគ្រប់គ្រងបានល្អ**

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវមានអភិបាលកិច្ចល្អ និងការគ្រប់គ្រងល្អ ដើម្បីជំរុញឱ្យផ្នែកឯកជន មានទំនុកចិត្តលើមជ្ឈមណ្ឌលនេះ ។ មជ្ឈមណ្ឌលនេះត្រូវតែមានការត្រួតពិនិត្យ និងការរក្សាតុល្យភាព ដើម្បីធានាថា ក្រុមប្រឹក្សាប្រតិបត្តិរបស់មជ្ឈមណ្ឌល ទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន ចំពោះសមាជិករបស់ខ្លួន ព្រមទាំងដើម្បីធានាថា មជ្ឈមណ្ឌលមានវិធានគ្រប់គ្រង និងប្រព័ន្ធល្អៗសំរាប់គ្រប់គ្រងការងារប្រចាំថ្ងៃ ។ មជ្ឈមណ្ឌលនេះត្រូវមានតុល្យភាព រវាងតួនាទីដឹកនាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ និងការចាត់ចែងប្រចាំថ្ងៃរបស់សេនាធិការដ្ឋានដែលមានភារៈកិច្ច ធ្វើការងារអនុវត្តន៏ ប៉ុន្តែមិនមែនការងារសំខាន់ៗដូចជាការគ្រប់គ្រងករណីបណ្តឹង ការវាយតម្លៃពាក្យសុំចូលជាសមាជិក និងទំនាក់ទំនងសាធារណៈទេ ។ ប្រការដែលសំខាន់គឺសេចក្តីណែនាំនីតិវិធីគោលនយោបាយសកម្មភាពរបស់មជ្ឈមណ្ឌល និងមជ្ឈត្តវិនិច្ឆ័យ ត្រូវមានមូលដ្ឋានច្បាស់លាស់ និងត្រូវធ្វើឡើងជាលាយលក្ខអក្សរ ។

- **មជ្ឈត្តករត្រូវមានគុណសម្បត្តិខ្ពស់ និងមានគេគោរព**

*កត្តាសំខាន់បំផុតដែលជួយឱ្យមជ្ឈមណ្ឌលនេះអាចទទួលបានជោគជ័យ គឺមជ្ឈត្តករត្រូវមានគុណសម្បត្តិល្អ ហើយត្រូវចេញមជ្ឈត្តវិនិច្ឆ័យដោយយុត្តិធម៌ ។ បើមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករប្រកបដោយភាពយុត្តិធម៌ ដែលភាគីវិវាទ អាចទទួលយកបាន ហើយមិនប្តឹងឧទ្ធរណ៍មជ្ឈត្តវិនិច្ឆ័យនេះទេ វានឹងធ្វើឱ្យមជ្ឈមណ្ឌលនេះមានឈ្មោះល្បី ។ អាជីវករនឹង ប្រើប្រាស់សេវារបស់មជ្ឈមណ្ឌលនេះកាន់តែច្រើន ។*

**ឯកឧត្តម ម៉ៅ ថូរ៉ា**

**អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម**

កត្តាសំខាន់បំផុតសំរាប់រាល់ស្ថាប័នច្បាប់ដែលល្អៗ គឺការចេញសេចក្តីសម្រេចចិត្តប្រកបដោយគុណភាពរួម ។ មជ្ឈត្តករ ត្រូវតែមានឯករាជ្យភាព ហើយមនុស្សទាំងឡាយដែលគេជ្រើសរើសអោយធ្វើជាមជ្ឈត្តករដំបូងគេ ត្រូវតែជាមនុស្សដែលមានគុណសម្បត្តិល្អជាងគេបង្អស់នៅក្នុងប្រទេសកម្ពុជា ។ គេគួរតែផ្តល់អាទិភាពដល់ អ្នកទាំងឡាយណា ដែលធ្លាប់មានបទពិសោធន៏ក្នុងការងារមជ្ឈត្តកម្ម ឬមានបទពិសោធន៏ធ្វើការទាក់ទងនឹងច្បាប់ពាណិជ្ជកម្ម និងជាមួយអាជីវកម្ម ។ សំរាប់មជ្ឈត្តករក្រុមដំបូងគេ គេត្រូវជ្រើសរើសចេញពីមជ្ឈដ្ឋានជាច្រើន ដើម្បីបង្ហាញពីឯករាជ្យភាព និងសមត្ថភាព ។ ប្រសិនបើ មានការជ្រើសរើសមជ្ឈត្តករដំបូងគេចេញពីមួយក្រុមតូច នោះអាចនាំអោយ មាន ការយល់ឃើញថាស្ថាប័ននេះមានមជ្ឈត្តករ ដែលមានគុណភាពមិនល្អ និងខ្វះឯករាជ្យ ។

*យើងគួរធ្វើការម្តងមួយតំណាក់ៗក្នុងការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ដើម្បីធានាថាមជ្ឈមណ្ឌលនេះមានមជ្ឈត្តករដែលមានគុណសម្បត្តិល្អ ហើយមជ្ឈមណ្ឌលនេះមានកេរ្តិ៍ឈ្មោះល្អ ។ មធ្យោបាយមួយដើម្បីជំរុញមជ្ឈមណ្ឌលនេះ គឺប្រហែលជាត្រូវឱ្យមានមជ្ឈត្តករបរទេសជាសមាជិកនៃមជ្ឈមណ្ឌលនេះ ។ ខ្ញុំគិតថា ការណ៏នេះអាចធ្វើមនុស្សដែលមាន គុណសម្បត្តិល្អជឿជាក់មកលើមជ្ឈមណ្ឌល និងចុះឈ្មោះជាមជ្ឈត្តករនៅមជ្ឈមណ្ឌលនេះ ។*

**លោក Tan Siah Yong**

**សហកម្មសិទ្ធករក្រុមហ៊ុន PIAH, TAN &PARTNERS**

មជ្ឈមណ្ឌលនេះក៏ត្រូវការផងដែរ នូវប្រព័ន្ធដ៏ល្អ និងមិនលំអៀងដើម្បីធានាថា នាពេលអនាគត អ្នកដែលមានសមត្ថភាពអាចក្លាយទៅជាមជ្ឈត្តករបានយ៉ាងងាយ និងថា គ្មានការរើសអើង ឬការជំទាស់នឹងពាក្យសុំចូលជាសមាជិក របស់អ្នកដែលមានគុណសម្បត្តិខ្ពស់ឡើយ ។ សេចក្តីសម្រេចបដិសេធពាក្យសុំធ្វើជាមជ្ឈត្តករ ត្រូវតែធ្វើឡើងជាលាយលក្ខអក្សរ ដោយមានការបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។

មជ្ឈត្តការមានគុណសម្បត្តិល្អជាងប្រព័ន្ធតុលាការត្រង់ថា អាជីវករមានសិទ្ធិជ្រើសរើសមជ្ឈត្តកររបស់ខ្លួន ហើយប្រការនេះការពារអាជីវករមិនឱ្យជ្រើសរើសមជ្ឈត្តករដែលខ្សោយ និងគ្មានបទពិសោធន៏ ហើយនេះជួយធានានូវការជឿទុកចិត្តលើស្ថាប័ននេះ ។ ហេតុនេះហើយ គេចាំបាច់ត្រូវផ្តល់ភាពងាយស្រួលអោយភាគីទាំងឡាយ អាចជ្រើសរើស មជ្ឈត្តកររបស់ខ្លួន ដោយរួមទាំងមជ្ឈត្តករមកពីបរទេស ដូចជាប្រទេសថៃ ឬសិង្ហបុរី ប្រសិនបើមជ្ឈត្តករទាំងនោះមានសមត្ថភាពសមស្រប ។

*ការជោគជ័យរបស់មជ្ឈមណ្ឌលមជ្ឈត្តការអាស្រ័យលើកត្តាជាច្រើន ។ កត្តាសំខាន់មួយគឺត្រូវធានាថាមជ្ឈត្តករមានឯករាជ្យភាព ។ ខ្ញុំគិតថា មជ្ឈមណ្ឌលត្រូវបង្កើតក្រមសីលធម៌មួយសម្រាប់ឱ្យមជ្ឈត្តករគោរពតាម ដែលនេះអាចធានាថា មជ្ឈត្តករមិនលំអៀងក្នុងការចេញមជ្ឈវិនិច្ឆ័យទេ ។*

**លោក លី តៃសេង**

**អគ្គលេខាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

មជ្ឈត្តករ ត្រូវការឱកាសបណ្តុះបណ្តាល ពីសំណាក់គ្រូបណ្តុះបណ្តាលក្នុងប្រទេស ឬមកពីបរទេស ហើយប្រការសំខាន់គឺ ការបណ្តុះបណ្តាលទាំងនោះត្រូវមានជាបន្តបន្ទាប់ និងត្រូវជាប់ជាករណីយកិច្ចចំពោះមជ្ឈត្តករគ្រប់រូបដែលបានចុះបញ្ជី ដើម្បីធានាថាមជ្ឈមណ្ឌលនេះលើកកំពស់បទដ្ឋានរបស់ខ្លួនជានិច្ច ។

- **ការចេញផ្សាយមជ្ឈត្តវិនិច្ឆ័យជាសាធារណៈ**

ការបោះផ្សាយមជ្ឈត្តវិនិច្ឆ័យ អាចជួយឱ្យគេមានទំនុកចិត្តលើមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ហើយជួយធានាថា ការដោះស្រាយវិវាទមានភាពយុត្តិធម៌ និងជួយកាត់បន្ថយការប្តឹងឧទ្ធរណ៍របស់ភាគីជម្លោះណាមួយ ។ មូលហេតុមួយ ដែលធ្វើឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល កសាងបាននូវការទទួលស្គាល់ពីសំណាក់សាធារណៈជននោះគឺ ដោយសារក្រុមប្រឹក្សានេះ បោះពុម្ពផ្សាយសេចក្តីសម្រេចរបស់ខ្លួន ។ ការបោះផ្សាយមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈមណ្ឌលបង្ហាញពីការទុកចិត្តលើមជ្ឈមណ្ឌល ។ ប៉ុន្តែ ដោយហេតុថា ជារឿយៗ គេត្រូវរក្សាការសំងាត់របស់ភាគីវិវាទពាណិជ្ជកម្ម ចាំបាច់មុនពេលបោះពុម្ពផ្សាយ គេត្រូវតែលុបចោលនូវព័ត៌មាន នានាដែលអាចបង្ហាញឱ្យដឹងអំពីអត្តសញ្ញាណនៃភាគីវិវាទ ។

- **តុលាការជួយគាំទ្រ ពោលគឺមិនបង្អាក់មជ្ឈត្តការទេ**

ប្រការមួយដែលមានសារៈសំខាន់នោះ គឺមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការទទួលបានការគាំទ្រ និងការចូលរួមពី ថ្នាក់ដឹកនាំប្រព័ន្ធតុលាការ និងប្រព័ន្ធតុលាការទាំងមូល ។ ដើម្បីឱ្យមជ្ឈមណ្ឌលនេះទទួលបានជោគជ័យ តុលាការគួរតែធានាថា មជ្ឈត្តវិនិច្ឆ័យត្រូវគេជំរុញអោយអនុវត្តយ៉ាងរហ័ស និងមានប្រសិទ្ធភាព ។ តុលាការមិនត្រូវពិនិត្យមើលមជ្ឈត្តវិនិច្ឆ័យឡើងវិញទេ លើកលែងតែក្នុងស្ថានភាពចាំបាច់បំផុត ដូចជាពេល ដែលមានភស្តុតាងជាក់ច្បាស់អំពីការបន្លំ ឬខុសឆ្គង ។

- **និរន្តរភាពផ្នែកហិរញ្ញវត្ថុ**

បើសិនជាគ្មានចំណូលដ៏សមស្របទេ វានឹងមិនអាចធានាអោយឱ្យមជ្ឈមណ្ឌលថ្មីនេះអាចបន្តសកម្មភាព ធ្វើការដោយគ្មានលំអៀង និងប្រកបដោយសីលធម៌ឡើយ ។ ពីដំបូង គេអាចរំពឹងថា សហគមអន្តរជាតិនឹងត្រូវជួយផ្តល់មូលនិធិ សំរាប់ទ្រទ្រង់ប្រតិបត្តិការរបស់មជ្ឈមណ្ឌលនេះ ។ ប៉ុន្តែ តាមបទពិសោធន៍ជាក់ស្តែង ការណ៍នេះនឹងទាមទារឱ្យមានតម្លាភាព និងឯករាជ្យភាពរបស់មជ្ឈមណ្ឌល ពុំនោះសោតទេ អង្គការអន្តរជាតិ នឹងស្ទាក់ស្ទើរក្នុងការផ្តល់មូលនិធិដល់មជ្ឈមណ្ឌលនេះ ។ សំរាប់រយៈពេលមធ្យមទៅវែង មជ្ឈមណ្ឌលនេះនឹងត្រូវកសាងរបៀបរកប្រាក់ចំណូលមួយ ដែលធានាអោយគេអាចរក ប្រាក់ចំណូលពីប្រតិបត្តិការរបស់គេផ្ទាល់បានគ្រប់គ្រាន់ សំរាប់ទ្រទ្រង់ខ្លួនឯង ។

## តើអាជីវកម្មគាំទ្រការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការនេះទេ?

*ខ្ញុំគិតថា មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការនឹងផ្តល់អត្ថប្រយោជន៍ដល់ផ្នែកឯកជនជាងប្រព័ន្ធតុលាការ ។ គេរំពឹង ថាមជ្ឈមណ្ឌលនេះមានមជ្ឈត្តករដែលមានបទពិសោធន៍ច្រើន ដែលអាចជួយដោះស្រាយវិវាទអាជីវកម្មបានលឿន ។ ទោះជាយ៉ាងណាក៏ដោយ គេអាចទទួលអត្ថប្រយោជន៍នេះបានតែក្នុងករណីដែលស្ថាប័ននេះមានឯករាជ្យភាព និងគ្មានអំពើ ពុករលួយ ហើយប្រសិនបើមជ្ឈត្តវិនិច្ឆ័យត្រូវតុលាការអនុវត្ត ។*

លោក ព្រំ វិសុទ្ធ
ប្រធាននាយកដ្ឋាននីតិកម្ម និងអនុប្រធានជាន់ខ្ពស់
ធនាគារ អេ ស៊ី លី ដា ភី អិល ស៊ី

ការសិក្សាស្រាវជ្រាវរបស់ IFC MPDF ក្នុងខេត្ត-ក្រុង ៥ ដែលធំជាងគេបង្ហាញថា អាជីវកម្មភាគច្រើនត្រូវការកំណែទម្រង់ច្បាប់ដ៏មានប្រសិទ្ធិភាព និងបាន ស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះគំនិតបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការនេះ ដោយមើលឃើញថានេះជាជំរើសដ៏មានតម្លៃមួយ សម្រាប់ដោះស្រាយវិវាទពាណិជ្ជកម្ម ។ ក្នុងពេលជាមួយគ្នានេះ ពួកគេមិនទាន់បញ្ជាក់ច្បាស់លាស់ថាពួកគេត្រៀមខ្លួននឹងប្រើសេវារបស់មជ្ឈមណ្ឌលនេះទេ ។ ពួកគេក៏បានបង្ហាញពីក្តីបារម្ភទាក់ទងនឹងឯករាជ្យភាពរបស់មជ្ឈមណ្ឌលនេះ ថ្លៃចំណាយ គុណភាព និងការអនុវត្តន៍ មជ្ឈត្តវិនិច្ឆ័យ ។ អាជីវកម្មភាគច្រើនពោលបញ្ជាក់ថា ស្ថាប័នបែបនេះត្រូវតែឯករាជ្យ ពីរដ្ឋាភិបាល និងពីប្រព័ន្ធតុលាការ ព្រមទាំងបាននិយាយថា ស្ថាប័នបែបនេះគួរតែមានការគាំទ្រពីសំណាក់ស្ថាប័នអន្តរជាតិឯករាជ្យ និងគួរឱ្យជឿទុកចិត្តបានមួយ ដើម្បីកសាងទំនុកចិត្តពីមជ្ឈដ្ឋានពាក់ព័ន្ធទាំងឡាយ ។

ជោគជ័យនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលរបស់កម្ពុជា អាចបង្ហាញពីឆន្ទៈក្នុងការប្រើប្រាស់សេវាមជ្ឈត្តការ ថ្វីបើ ក្នុងករណីក្រុមប្រឹក្សាអាជ្ញាកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជូនករណីបណ្តឹងទាំងអស់ទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយគេទាមទារឱ្យភាគីវិវាទដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ដោយ ។ ផ្ទុយទៅវិញ ការប្រើប្រាស់សេវារបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការថ្មីគឺនឹងធ្វើឡើងតាមលក្ខណៈស្ម័គ្រចិត្តទាំងស្រុង ។ នេះបញ្ជាក់ថា វាជាការចាំបាច់ដែល គេត្រូវតែបង្វែការគាំទ្រជាគោលការណ៍របស់សមាគមអាជីវកម្ម ឱ្យទៅជាតម្រូវការជាក់ស្តែង សំរាប់សេវារបស់មជ្ឈមណ្ឌលដោះស្រាយ វិវាទក្រៅប្រព័ន្ធ តុលាការ ។

## សេចក្តីសន្និដ្ឋានៈ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ជាជំហានមួយឆ្ពោះទៅរកទិសដៅដ៏ត្រឹមត្រូវ

បទពិសោធន៍IFC បានបង្ហាញថា ការបង្កើតស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដូចជាការផ្សះផ្សារ និងមជ្ឈត្តការអាចជួយកែលំអបរិយាកាសអាជីវកម្ម ដោយផ្តល់នូវជំរើសសម្រាប់ ដោះស្រាយវិវាទថ្មីមួយដែលមានប្រសិទ្ធិភាព ។ កំណែទម្រង់បែបនេះ មានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ដែលភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់ពាណិជ្ជកម្ម រារាំងវិនិយោគ ដែលអាចជំរុញឱ្យប្រទេសនេះមានកំណើនសេដ្ឋកិច្ចកាន់តែខ្លាំងជាងបច្ចុប្បន្ននេះទៅទៀត ។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ មានសក្តានុពលក្នុងការកែលំអបរិយាកាសអាជីវកម្ម ដោយផ្តល់ឱ្យអាជីវកម្មជំរើស មួយទៀតដែលគេត្រូវការបន្ថែមពីលើយន្តការដោះស្រាយវិវាទនាពេលបច្ចុប្បន្ន ។ មជ្ឈមណ្ឌលក៏អាច កែលំអបរិយាកាសអាជីវកម្ម ដោយកែលំអការជឿទុកចិត្តរបស់អាជីវកម្ម និងបង្ហាញពីឆន្ទៈរបស់រដ្ឋាភិបាលក្នុងការជំរុញឱ្យមានបរិយាកាសច្បាប់ និងបទបញ្ញត្តិប្រសើរជាងមុន ។ ថ្វីបើមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការគឺជា ជំហានមួយក្នុងទិសដៅដ៏ត្រឹមត្រូវក៏ដោយ វាជាការសំខាន់ដែលគេត្រូវទទួលស្គាល់ថា ស្ថាប័នច្បាប់ថ្មីមួយនៅប្រទេសកម្ពុជា ទំនងជាជួបប្រទះនឹងការប្រឈមមុខនឹង ការលំបាកក្នុងការបង្កើតស្ថាប័ននេះ ។ ចំពោះមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ដែលពឹងផ្អែកលើតម្រូវការដោយស្ម័គ្រចិត្ត ពីអាជីវកម្ម មជ្ឈមណ្ឌលនេះត្រូវតែ ឯករាជ្យ យុត្តិធម៌ និងមិនលំអៀង និងផ្តល់ការដោះស្រាយវិវាទដែលមាន គុណភាពខ្ពស់ និងចំណាយតិចតាំងពីពេលដំបូង ។ បើមិនដូច្នេះទេ វាប្រហែលជាមិនបង្កើតឱ្យមានការប្រើប្រាស់សេវារបស់មជ្ឈមណ្ឌលនេះ ដើម្បីធ្វើឱ្យមជ្ឈមណ្ឌលនេះទទួលបានជោគជ័យទេ ។


រក្សាសិទ្ធិ MPDF 2007
Publisher: MPDF No. 70, Norodom Blvd., Phnom Penh
Tel: (855)-23-210-922 Fax: (855)-23-215-157
E-mail: shor@ifc.org Website: www.mpdf.org
Layout by: Kea Kunthea
Printed by: MAKARA Printing House